# ការសំភាសន៍ជាលើកទី២របស់អ៊ុំស្រី សេង ទូច

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ សេង ទូច

**ការសង្ខេបរបស់អ៊ុំស្រី សេង ទូច**

នៅក្នុងការសំភាសន៍ជាលើកទី២នេះ អ៊ុំស្រីសេងទូចគាត់បានរៀបរាប់ពីជីវិតគាត់កាលពីនៅក្នុងរបបសង្គ្រាម ថាកូនគាត់ត្រូវបានស្លាប់ពេលជំនាន់ហ្នឹងហើយដោយសារអត់បាយហូបគឺទាររកបាយហូប ហើយគាត់គ្មានអ្វីដែលអោយកូនញុំាហើយគាត់អោបហើយកូនទន់ទៅៗក៏ស្លាប់ទៅ។ អ៊ុំស្រីបានរៀនដល់ថ្នាក់ទី៧សម័យពីដើមហើយគាត់បានរៀបការជាមួយស្វាមីគាត់ហើយស្វាមីជាទាហានលន់ នល់ហើយត្រូវគ្រាប់ចំសូតក៏ស្លាប់បាត់ទៅហើយក្នុងជំនាន់ប៉ុលពតគេបានរៀបអោយគាត់មានស្វាមីមួយទៀត បើមិនយកគេនឹងជំលៀសអោយទៅនៅកន្លែងមួយដែលពិបាកហើយគាត់ក៏ព្រមយកស្វាមីជាលើកទី២ទៅ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំស្រីដែលបានអោយខ្ញុំសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ុំ នាង់ខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍នៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍គឺនៅក្នុង ខែមិនាឆ្នាំ ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជាអ៊ីចឹងពេលមុនញ៉ុមបានសំភាសន៍អំពីជីវិតរបស់អ៊ុំបានច្រើនហើយតែនៅកន្លែងខ្លះដែលគាត់ចង់និយាយពីជីវិតរបស់គាត់បន្ថែមទៀត គាត់បានឆ្លងកាត់នៅក្នុងរបបសង្គ្រាមក៏ដូចជាជីវិតរបស់ក្រុមគ្រួសារអ៊ុំស្រីផ្ទាល់ផងដែរ អញ្ចឹងនាងខ្ញុំសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ុំ ពីជីវិតរបស់អ៊ុំមានដូចតទៅ !!អ៊ុំសូមប្រាប់ឈ្មោះពេញម្តងទៀតមើលអ៊ុំ?

ខៈ ញ៉ុមឈ្មោះ!!

កៈ សេង ទូច អ៊ុំហេ?

ខៈ ចាំ!!!

កៈ សេង ទូចហ្នឹងហើយ!!អញ្ចឹងអ៊ំសំរាប់ចូលដល់ការសិក្សារបស់អ៊ំហាំ
អ៊ំរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈ ទី៧កូន។

កៈ ទី៧ពេលជំនាន់សង្គមចាស់?

ខៈ ចាំ!!

កៈ ចាំអញ្ចឹងអ៊ំពេលកាលអ៊ំរៀនហ្នឹងអ៊ំរៀនសាលាបឋមសិក្សាឈ្មោះអីគេដែរ?

ខៈ សាលាបឋមសិក្សាភូមិត្នោតក្រោម។

កៈ ត្នោតក្រោម?

ខៈ ចាំ!!

កៈ សាលាបឋមសិក្សាត្នោតក្រោមអញ្ចឹងម៉ង?

ខៈ ចាំ នៅឯស្រុកហ្នឹងម៉ង!!

កៈ ចាំ និយាយទៅ!!ចាំរៀនសាលាបឋមសិក្សាតើអ៊ំហេ អត់មានចូលអនុណាអ៊ំហេ?

ខៈ
ចាំបានទៅចូលអនុតែដល់បានតែដល់ថ្នាក់ទី៧ហ្នឹងញ៉ុមក៏ឈប់ទៅមកធ្វើការនៅភ្នំពេញណេះណាស់!!

កៈ ចាំ!!

ខៈ ថាមកធ្វើការធ្វើអីនៅភ្នំពេញ ព្រោះយើងក្រមុំហើយ។

កៈ ចាំ!!

ខៈ ធំហើយអាយុប្រហែល១៦ ១៧ហើយ ១៦ ១៥ហើយ។

កៈ ចាំ!!

ខះ ចាប់ផ្តើមបែកពីម៉ែមកនៅភ្នំពេញម្តាយរបស់យើងកាលហ្នឹងយ៉ាប់ណាស់។

កះ ហ៊ុំ!!ចាប់ផ្តើមចូល !អ៊ំធ្វើការអីគេមកភ្នំពេញ?

ខះ ញ៉ុមមកភ្នំពេញធ្វើការរោងចក្រ។

កះ រោងចក្រអីគេវិញអ៊ំ?

ខះ រោងចក្រត្បាញប្រែអញ្ចឹងណាស់ អាប្រែមួយអារ អាពីដើមហ្នំអូន ស្គាល់អត់?

កះ ប្រែអីគេអ៊ំ?

ខះ ប្រែមួយអា មួយអាពីដើមហ្នំ!!ចាស់ៗពីដើមចំនាំស្លៀកហា៎!! ប្រែមួយរលោង រលោងហា៎!!!

កះ ចា៎ចា៎!!

ខះ ពីដើមមកចាស់ពីស្លៀកហ្នឹង ធ្វើរោងចក្ររាល់ថ្ងៃហ្នឹង
ធ្វើការរាល់ខែទៅណាស់បានលុយមកទៅយកទៅជូនម្តាយខ្លះទៅ ចាយលុយហ្នឹងខ្លះទៅ។

កះ ហើយអ៊ំមកម្តាយនៅស្រុកទេណោះហ្នឹង?

ខះ នៅស្រុកទេគាត់នៅជាមួយប្អូន បងប្អូនស្រុកទៅ។

កះ ហើយអ៊ំមកនៅជួលផ្ទះគេនៅហីអី?

ខះ មកនៅកន្លែងក្នុងរោងចក្រហ្នឹង។

កះ ហ្នំអ៊ីចឹងគេមានកន្លែងអោយនៅ!!

ខះ ពីដើមគេមានកន្លែងអោយនៅចា៎!!

កះ ស្រួលហើយអ៊ីចឹង។

ខះ នៅអ៊ីចឹងទៅដល់ពេលយើងនៅ ធ្វើនៅឫស្សីកែវ នៅគីឡូលេខ៣កន្លះនេះ។

កះ ចា៎!!

ខ៖ នៅផ្ទះបាយគេធ្វើនៅមកទន្លេអ៊ីចឹងទៅ រោងចក្រអញ្ចឹង
រោងចក្រនៅខាងហ្នឹងអ៊ីចឹងនៅផ្លូវហ្នឹងគេមានធ្វើផ្ទះបាយគេ ផ្ទះគេផ្ទះនៅក្នុងឯងហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ ផ្ទះបាយយើងដាក់ខែគេទៅ។

ក៖  ចាំ តែកន្លែងគ្រាន់តែគេអោយនៅបាយទឹកលើខ្លួនឯង ?

ខ៖ ខ្លួនឯង ដល់ពេលចុះទៅហូបទៅ មកកន្លែងមក ដល់ពេលចូលធ្វើការចូលធ្វើការ៦ម៉ោង
ក្នុងមួយថ្ងៃ៦ម៉ោង។

ក៖  ហ៊ីតិចម្ល៉េះអ៊ំ?

ខ៖  មិនមែន៦ម៉ោង ៦ម៉ោង វា១២ តែធ្វើម្តងវា៦ម៉ោង ចូលពីម៉ោង៦ចេញម៉ោង១២
ដល់ម៉ោង៦យប់ចេញម៉ោង១២យប់អញ្ចឹងទៅ!!

ក៖ ហ្ហ៎អញ្ចឹងពីរវេន?

ខ៖  ពីរវេន។

ក៖ អញ្ចឹងមួយវេនម្តង៦ម៉ោង។

ខ៖  ពីរវេន យើងចេញគេចូល គេចូលយើងចេញ។

ក៖  ហ្ហ៎អ៊ីចឹងមួយថ្ងៃ១២ម៉ោង?

ខ៖  ហ្នឹងហើយគេចូលអញ្ចឹងទៅ ជួនណាលអា៦ដល់ម៉ោង១២ហ្នឹង អត់អីទេណាស់
អាកំពុងតែដេកលក់ ចូលម៉ោង១២។

ក៖ ហើយថីមិនព្រមអោយធ្វើជាប់គ្នាមួយថ្ងៃវាស់ល្ងាចទៅអត់ទេ?

ខ៖  អត់ទេក្រោកមកអង្គុយក្នុងមុង
អើយកំសត់ខ្លួនណាស់ក្នុងមុងមកលុបមុខដុសធ្មេញទំរាំតែចូលទៅធ្វើការហ្នឹង

តាំងពីញុំមនៅក្រមុំ ងោកងោកហ្នឹងដល់ពេលទៅមើលទៅម៉ែមូលចូលទៅ វាអស់ វាអស់អំបោះហ្នំ!!!

កៈ ចាំ!!

ខៈ អស់អំបោះវាពីខាលនោះ!!

កៈ  ហ្នឹងហើយ។

ខៈ ចូលទៅប្រវែងហ្នឹងរវ៉ៃទៅមូលអាក្រោយអញ្ចឹងទៅម៉ាអញ្ចឹងទៅ បានដាក់អាថ្មីទៅ។

កៈ ចាំដល់ពេលនេះទៅបានលុបមុខលុបអីអញ្ចឹងទៅបានដល់ម៉ោង២ហើយ។

កៈ ចាំ!!

ខៈ ក្រោកឡើងម៉ោង១២ម៉ោង១ ម៉ោង២អីបានអង្គុយងោក ងោកទៀតហើយ!!ទំរាំតែដល់ម៉ោង៦ចង់នេះ ប៉ុន្តែរួចបានមួយយប់អញ្ចឹងទៅ!!ហើយស្អែកឡើងហ្នឹងអីចឹងទៀតទៅ!!គេអោយយើងធ្វើក្នុងមួយពេលអីចឹងមួយអាទិត្យហ្នឹងអីចឹងម្នាក់ទេ មិនមែនធ្វើមួយខែទេ !! ធ្វើមួយអាទិត្យគេយើងមួយអាទិត្យយើងអីចឹងទៅ។

កៈ ហ្នំអីចឹងវាបានឆ្លាស់គ្នាដែរ!!

ខៈ  ឆ្លាស់គ្នាហ្នឹងហើយ ។

កៈ ចាំ!!

ខៈ ជួនកាលយើងចូលម៉ោង៦ចេញម៉ោង១២ ជួនកាលគេចេញម៉ោង១២យើងចេញម៉ោង៦ភ្លឺអីចឹងទៅ!!

កៈ ហ៊ុំ!!

ខៈ ម៉ោង៦ភ្លឺយើងក្រោកឡើងបានយើងចូលអញ្ចឹងទៅទៀតទៅ។

កៈ ចាំ!!

ខះ ចូល១២អញ្ចឹងទៅម៉ោង៦ល្ងាចបានយើងចូលអញ្ចឹងទៅ។

កះ  នៅក្នុងរោងចក្រហ្នឹងថ្លង់ទេអ៊ំម៉ាស៊ីន?

ខះ  ថ្លង់ ខែខា ខែខានេះនោះវានេនោះត្រង់វាដើរ វារៃសុទ្ធតែម៉ាស៊ីនហ្នំ!!

កះ ចាំ!!

ខះ ហើយមួយខែបានតែនេះទេ បានមួយខែបាន៥០០ទេណាស់មួយខែ!!

កះ តែថ្លៃអ៊ំហេកាលហ្នឹង?

ខះ  ថ្លៃកាលហ្នឹង ងាប់ហើយមានតែ២០០ ៣ ៥០០
២០០ហ្នឹងដើរទិញអីចង់ឆ្អែត។នៅជំនាន់ហ្នឹងគុយទាវមួយចានតែ៣០០ហ្នឹង
(គាត់ប្រហែលជាច្រឡំប្រហែលតែ៣រៀល)មួយចាន៣០០យប់ឡើងអង្គុយដេកហ្នឹង
ទិញគុយទាវហូបទៅ។

កះ ៣រៀលឬក៏៣០០គុយទាវ?

ខះ  ហ្នំ៣រៀល។

កះ ហ្នំ៣រៀលទេហោ?តែបើមាន៣០០គឺច្រើនតែម្តង?

ខះ  ចាំច្រើន!!មួយអាទិត្យមិនមែនមួយខែទេ មួយអាទិត្យធ្វើការបាន៣០០
៥០០អីចឹតងទៅណាស់ ច្រើនណាស់ ស្រួលណាស់កាលហ្នឹង។

កះ  ចាំហ្នឹងហើយ!!

ខះ  មួយខែបាន១០០០អីដែរ!!

កះ ចាំ !!

ខះ ១០០០ជាងអីដែរ។

កះ  ពេលហ្នឹងជំនាន់សង្គមរាស្ត្រនិយមស្តេចគ្រប់គ្រងហ្នឹងអ៊ំហេណោះ?

ខ៖  ហ្នឹងហើយ សង្គមរាស្ត្រនិយមពេញម៉ង!!

ក៖ ចាំ!!

ខ៖ កាលហ្នឹងស្តេចនៅក្មេងទេណាស់!!

ក៖ ចាំ!!

ខ៖ ហ្នឹងហើយអាយុប្រហែល២០ជាងអីហ្នឹង!!

ក៖  ហ្នឹងហើយពេលហ្នឹងស្រុកសុខសប្បាយណាស់អ៊ំណោះ?

ខ៖  ហ្នឹងហើយ។

ក៖  ហ៊ី!! អ៊ំពេលនៅរៀនហ្នឹងពួកម៉ាក់អីច្រើនទេ?មានពួកម៉ាក់?

ខ៖
មានវាចេះតែមានច្រើនហើយប៉ុន្តែគេអ្នកនៅស្រុកស្រែចំការទៅណាក៏ត្រូវតែស្គាល់គាត់រាប់អាន
ដែរណាស់។

ក៖ ចាំ!!

ខ៖ គេស្រលាញ់រាប់អានញ៉ុមណាស់ និយាយទៅមនុស្សញ៉ុមមនុស្សសំបូរបរិវាណាស់
សំបូរម៉ង!!សំបូរគេស្រលាញ់ញ៉ុមណាស់គេចូលចិត្តញ៉ុមណាស់ទាំងប្រុសទាំងស្រី!!

ក៖ ចាំ!!

ខ៖ គេរៀងចូលចិត្ត ទៅណាគេក៏អត់ស្អប់ញ៉ុមដែរ!!

ក៖  ហ្នឹងហើយ។

ខ៖ នៅកន្លែងណាក៏មនុស្សញ៉ុម ញ៉ុមអត់សូវចេះមាត់កូន ទៅណាញ៉ុមចេះតែញឹមៗ
ចាស់ក្មេងអីគេចូលចិត្តញ៉ុម។

ក៖ ចាំ!!

ខ៖ តែដល់ពេលមកចាស់ទៅយើងក្រយើងមិនសូវសំបូរគេមិនសូវរាប់ទេ!!

ក៖ ហ៊ឺៗ!!

ខ៖
បើពីដើមមីអូននៅពីក្មេងពីក្រមុំមិនខ្វះទេពួកម៉ាក់មានកូនមួយកូនពីរទៅបើកទ្វារមកមកហើយពួកម៉ាក់មិនសូវខ្វះអីស៊ីទេ មកដូចហ្នែងមកលេងអ៊ីចឹង។

ក៖ ចា៎!!

ខ៖ យកមកហើយ។

ក៖ ចា៎!!

ខ៖ ថ្ងៃអាទិត្យអីដឹងតែមកហើយ។

ក៖ ហ៊ឺៗ!!

ខ៖ នាំគ្នាចាក់បាញ់ផ្សែរ នាំគ្នាធ្វើត្រីដុតអីអញ្ចឹងទៅ!!នាំគ្នាស៊ីរហូត!!ឧស្សាហ៍តែលាងចានហ្នឹងមិនចាំបាច់អស់លុយទេ!!

ក៖ តែឥឡូវពួកគាត់សុទ្ធតែបែកគ្នារៀងៗខ្លួនហើយអ៊ំហេ?

ខ៖ បែកគ្នាអស់ហើយកូនអើយ
បែកគ្នាអស់ខ្លះងាប់អស់ហើយមើលទៅកូនអើយមិនដឹងទៅណាទៅណីចំណាស់ៗនេះអស់ហើយ។

ក៖ តែបាត់អស់រលីងហើយអ៊ំណេះ?

ខ៖ នៅជំនាន់អាពត មាន មាននៅសល់ខ្លះដែរ!!ចា៎!!

ក៖ ហ្ហ៎!!អ៊ំមិត្តភក្តិជិតស្និតជាងគេឈ្មោះអីគេវិញ?

ខ៖ មិត្តភក្តិជិត មិត្តភក្តិជិតស្និតឈ្មោះស្រីឡូន។

ក៖ ស្រីឡូន?

ខៈ ចាំស្រីឡូន។

កៈ តែគាត់នៅរស់ដល់សព្វថ្ងៃទេអ៊ំហោ?

ខៈ អត់ដឹងទេកូនបែកគ្នាតាំងពីបែកអាពតមកមិនដែលជួបគ្នាទេ
តែគ្រាន់តែឮសួរថានៅរស់ដែរ ប៉ុន្តែស្លាប់អស់ហើយទេមិនដឹង។

កៈ ហ៊ឺ!!

ខៈ គាត់បងញ៉ុមច្រើនដែរហ្នឹងហាំ!!

កៈ ចាំ!!

ខៈ គាត់ហ្នឹងអ្នកជីក អ្នកប្រមឹកហ្នឹងហាស្រីប្រមឹក!!អ៊ីចឹងហាំ!!

កៈ អើយគ្មានបាននៅរស់ទេ បើប្រមឹកជីកហើយហ្នឹង!!

ខៈ ហ្នឹងអាយុមិនសូវវែងទេចាំ បែកគ្នាតាំងពីជំនាន់លន់ នល់
មកបែកគ្នាមករហូតមិនដែលបានជួបគ្នាទេ!!

កៈ ហ៊ឺ!!

ខៈ
ហ្នឹងហើយស្រលាញ់ញ៉ុមណាស់អង្គរក្សញ៉ុមម៉ង!!ថាធ្វើការអីខោអាវញ៉ុមមិនដែលបោកទេអូន
។

កៈ ហ្នឹងហើយ!!

ខៈ ស្រាតពីខ្លួនហ្នឹងទៅហើយប៉ុនគ្នាគ្រាន់តែគេខ្មៅ។

កៈ ចាំ!!

ខៈ គេខ្មៅជាងខ្ញុំ។

កៈ ចាំ!!

ខៈ ប៉ុនមិនមែនដូចឥឡូវគេស្រលាញ់ស្រីៗគ្រាន់តែជាពួកម៉ាក់ទេ!!

កៈ ចាំ!!

ខៈ កាលពេលជំនាន់ហ្នឹងមិនដែលចេះស្រលាញ់ស្រីដូចគ្នាទេ។

កៈ ហ្នឹងហើយពេលមុនដូចថារាប់អានអ៊ំហេ?

ខៈ  រាប់អានពួកម៉ាក់!!រ៉ាប់អានដូចថាពួកម៉ាក់ រាប់អានងាប់រស់ដែរ។

កៈ ចាំ!!

ខៈ ស្រលាញ់គ្នា ស្រលាញ់គ្នាប្តូរជីវិតដូចថាមើលធ្វើ ខ្លាចអាណាធ្វើបាប ខ្លាចមានរឿង ចេញមុខជួស!!

កៈ ចាំ!!

ខៈ មិនមែនរាប់អានធ្វើឆ្កួតៗដូចឥឡូវហ្នឹងយកគ្នាធ្វើប្តីប្រពន្ធទេ!!

កៈ  ហ្នឹងហើយអ៊ំឥឡូវហ៎ាវិបត្តិកើតឡើងច្រើនណាស់អ៊ំ អារឿងស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុសហ្នឹង!!

ខៈ ចាំ!!

កៈ អួយអត់មានទេ អត់មានទេ ខ្ញុំ!!

កៈ
អ៊ំនៅថៃឥឡូវហ៎ា!!ញ៉ុមអត់ដឹងថាវាការពិតឬក៏អត់ទេតែញ៉ុមឮគេនិយាយថាសំបូរខ្ទើយប្រុស ខ្លាំងណាស់!!របៀបថាជួបវិបត្តិមួយគឺសុទ្ធតែខ្ទើយនៅក្នុងប្រទេសហ្នឹង!!

ខៈ  ហ្នឹង ហ្នឹង អ៊ីចឹងត្រូវហើយ!!
ហើយដូចថាស្រលាញ់ញ៉ុមណាស់គ្នាដូចថារ៉ាប់រងសព្វគ្រប់តាំងពីខោពីអាវ ខោអាវទៅកាត់អញ្ចឹងហ៎ា!!រហូតដល់ចង់អោយគេល្អចង់អោយគេល្អស្លៀកពាក់ទៅអ៊ុំទូកអ៊ីចឹង បុណ្យសីមាអ៊ីចឹងអោយគេស្លៀកពាក់មុន!!

កៈ ចាំ!!

ខៈ ស្លៀកពាក់មុនម្ដងពីរដងហាំបានយើងយកទៅពាក់។

កៈ ចាំ!!

ខៈ ស្រលាញ់ណាស់
ឧបមាថារាប់អានជាមួយហ្វែងអីចឹងហើយដល់ឃើញញ៉ុមស្ដីរកអាណាទៀតយំហើយខ្លាចញ៉ុមហ្នឹងបោះចោលវា ស្រលាញ់ណាស់!!

កៈ ច្រណែនអំណោះ?

ខៈ
ចាំ!!ច្រណែន!!ហ្នឹងហើយដូចពាក្យចាស់គេនិយាយថាដូចប្រចណ្ឌអីចឹងណាស់!!ប៉ុនមិនមែនដល់ថ្នាក់ប៉ុណ្ណឹងទេមិនមែនទេ អត់មានអញ្ចឹងទេ!!

កៈ អីចឹងអំចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់អំវិញម្ដង
អំរៀបការជាមួយស្វាមីគាត់ឈ្មោះអីគេដែរ?

ខៈ ស្វាមីដំបូងឡើយដែលបន្ទាប់ពីតាញ៉ុមហ្នឹងហេ?

កៈ អុញ !! អញ្ចឹងអំមានស្វាមី២អំណោះ?

ខៈ ពីរ ចាំកូន២។

កៈ អញ្ចឹងឥឡូវនិយាយពីអំប្រុសដំបូងមុនសិន។

ខៈ ដំបូងឡើយប្ដីញ៉ុមធ្វើទាហានជំនាន់លន់ នល់យើងហ្នឹង!!

កៈ ឈ្មោះអីគេវិញ?

ខៈ ប្ដីញ៉ុមមុនឈ្មោះយោក!!

កៈ យោក?

ខៈ ចាំហ្នឹងហើយ!!

កះ  អីគេយោក?

ខះ  ស្អីទេនេះញ៉ុមអត់ អត់ចាំផង!!

កះ  អត់ចាំ?

ខះ  អត់ចាំ!!

កះ  អត់ចាំត្រកូលទេប្តីទេហោ?ហើយគាត់ស្លាប់មូលហេតុអីគេអំ?

ខះ ស្គាល់ឈប់សិន!! ដល់ពេលទៅគាត់នៅកំពង់ឆ្នាំង
នៅស្អីកំពង់ឆ្នាំងនៅស្រុកកំពង់ត្រឡាចណោះស្រុកកំណើតគាត់ហ្នឹងហាំ!!

កះ ចាំ!!

ខះ បានទៅលេងម្តងដែរ!!ពេលហ្នឹងយើងមិនដាច់ផ្លូវមិនដាច់អីយើងទៅជំនាន់ហ្នឹង
យើងបានគ្នាមុនពេលលន់នល់ហ្នឹងយើងបានប្រហែល៣ ៤ ៥ឆ្នាំបានកូនតែមួយទេ!!

កះ ចាំ!!

ខះ ពេលហ្នឹងគាត់ស្លាប់គាត់ត្រូវគ្រាប់ ច្បាំងហ្នឹង!

កះ  ច្បាំងពេលអើរជំនាន់ហ្នឹង?

ខះ  ពេលសង្គ្រាមហ្នឹងពេលលន់ នល់ហ្នឹង!!

កះ  លន់ នល់ហ្នឹងហេ?

ខះ  ចាំ ពេលហ្នឹងលន់ នល់ហ្នឹង!!

កះ  អញ្ចឹងពេលលន់ នល់ហ្នឹងគាត់ធ្វើទាហានលន់ នល់?

ខះ  ហ្នឹងហើយដល់ពេលត្រូវគ្រាប់មកមកត្រូវស្វតកូនណាស់!! កះ ហ៊ឺ!!ខះ
កាលហ្នឹងគេដឹកស្អីអេឡេកូម កាលហ្នឹងញ៉ុមនៅបុរីកីឡាកូន
ជំនាន់ហ្នឹងហាកូនអើយគួរអោយខ្លាចណាស់!!

កៈ  ម៉េចវិញទៅអ៊ំមើល មើលប្រាប់មើល!!

ខៈ
គេឡើងគេវ៉ៃឡេក្វមមួយថ្ងៃៗចុះនៅកន្លែងបុរីកីឡាកន្លែងហ្នឹងវាចុះរួចបើវាវាលធំបុរីកីឡាយើងណោះហ្នឹងហាំ!!

កៈ ចាំ!!

ខៈ ញ៉ុមនៅក្នុងហ្នឹងធ្វើផ្ទះធ្វើអីនៅហ្នឹងដូចថាយើងសុំ យើងអីគេបានហើយហ្នឹងណាស់!!
ស្គាល់គេនៅហ្នឹងហាំ!!

កៈ ចាំ!!

ខៈ ចុះនៅហ្នឹង មួយថ្ងៃៗគ្រាន់តែអេឡេក្វមហ្នឹងចុះមួយថ្ងៃៗមិនដឹងប៉ុន្មានទេ។

កៈ អាឧត្តម្ភភេជ្ជៈហ្នឹងអីគេហ្នឹងអ៊ំណោះ?

ខៈ ចាំ??

កៈ  អាឧត្តម្ភភេជ្ជៈគេហ្នឹងហោ?

ខៈ  ហ្នឹងហើយ គេហៅអេឡេក្វម។

កៈ  ហ្នឹងហើយហោឡេកុមទ័រអង់គ្លេស។

ខៈ  អេឡេកុមទ័រហ្នឹងហើយ!!ហ្នឹងហើយ ដល់ពេលហើយចុះមកសែងអ្នករបួសយកមក
ប្រពន្ធប្រពន្ធមកឈរចាំមើលប្តីហើយ!!តាំងគេទាំងយើងអោយតែប្រពន្ធទាហាន។

កៈ  ចំាមើល អ្នកខ្លះស្លាប់ទៅអ្នកខ្លះនេះរស់អ៊ីចឹងទៅអ៊ំណោះ?

ខៈ  អ្នកខ្លះនៅរស់ គេនៅរបួស គេយកទៅពេទ្យទៅ គេទៅតាមទៅមើលកំដរទៅ!!គាត់
គាត់អត់ទាន់ងាប់ទេ ដល់ពេលគាត់នេះ គាត់ដេកពេទ្យបានយូរដែរបានគាត់ស្លាប់ហ្មុំ!!

កៈ ហ្មុំ!!

ខៈ ដល់គេថតទៅ គិតទៅសួតយើងហាត់អាក្រក់ផណាស់ ដូចគោអ៊ីចឹង។

កៈ  គាត់កើតជំងឺស្ងួត?ហាត្រូវគ្រាប់?

ខៈ  គ្រាប់ហ្នឹងត្រូវស្ងួត ត្រូវស្ងួត អង្គុយអត់អីអត់កើតទេ ផ្អែកតើ!

កៈ  វាជះម៉េចទៅអ៊ំណោះ?វាជះម៉េចបានដល់ថ្នាក់ដល់ក្នុងខ្លួនណោះ?

ខៈ  ខ្លួនហ្នឹងគេបាញ់មកត្រូវហ្នឹង!!

កៈ  ហ្នំបាញ់គ្រាប់ត្រូវទេអញ្ចឹងហេ?

ខៈ  ដូចថាយើង ដូចថាយើងបាក់ទ័ពអីអញ្ចឹងទៅគេបាញ់យើងត្រូវហាំ
វាគ្រោះថ្នាក់យើងបាញ់ត្រូវទៅ ហើយពេលហ្នឹងមិនមែនថាប្តីយើងប្តីគេ កូនយើងកូនគេទេ
ពេលចុះមកដាក់មកម្តងៗអ្នករបួសហាំ៤ ៥នាក់៣ ៤នាក់ គរលើគ្នាយកមកហើយ !!

កៈ ហ៊ី!!

ខៈ មកដល់ស្វែងឃើញហ្នឹង!!

កៈ  ពិបាកណាស់អ៊ំណោះ?

ខៈ  ហ៊ីវេទនាណាស់កាលជំនាន់លន់ នល់ហ្នឹង។

កៈ  ចាំហើយអញ្ចឹងអ៊ំពេលអ៊ំរៀបការជាមួយស្វាមីដំបូងទាំងអស់មានកូនប៉ុន្មាននាក់?

ខៈ  កូនតែមួយទេ គាត់ក៏ស្លាប់ទៅ!!

កៈ កូននៅរស់នៅដល់រាល់ថ្ងៃទេ?

ខៈ  ស្លាប់ហើយ ស្លាប់ជំនាន់ពត!!

កៈ អើយអ៊ំ!!ស្លាប់ទាំងអស់ហ្នឹង បានអាប្តីក្រោយនៅរស់ ក្រៅពីហ្នឹងស្លាប់អស់ហើយ!!!

កៈ ចាំ!!ចុះកូនឈ្មោះអីគេប្តីមុន?

ខៈ  កូនឈ្មោះអាខេ។

កៈ  អាខេ?

ខ៖ អូខេ!!

ក៖ អូខេល?

ខ៖ អូខេ។

ក៖ អូខេ?

ខ៖ ចាំដាក់តាមអ៊ុនតាក់នោះកាលពីជំនាន់ហ្នឹងមិនសំបូរអ៊ុនតាក់។

ក៖
អ៊ំញ៉ុមអត់ឃើញមានអ្នកណាគេឈ្មោះអូខេទេនេះ!!ស្រីឬក៏ប្រុស?ចាំអ៊ីចឹងអ៊ំកូនអ៊ំឈ្មោះអូខេ?
ខ៖ ចាំ!!ក៖ ត្រកូលអីគេអ៊ំ?

ខ៖ ត្រកូលនេះហ្នឹងស្អី!ប៉ាវា តាហោងហ្នឹងដាក់ហោង អូខេហ្នឹង!!

ក៖ ហោង អូខេ!!អាយុប៉ុន្មានបានស្លាប់?

ខ៖ កាលហ្នឹងដូចអាយុ៩ឆ្នាំហើយ ដូច៩ឆ្នាំ។

ក៖ ហ្ហ៎!!

ខ៖ ឈឺហើមនៅអាពតហាំ!!

ក៖ អត់មានអីហូបហ្នឹងអំណោះ?

ខ៖ អត់មានអីហូបកាលពីជំនាន់អាពតហ្នឹងហើមទៅទន់កករងោកហ្នឹងងាប់ទៅ!!

ក៖ អូយអានិតណាស់អ៊ំអើយ!!!ស្លាប់នៅដៃអ៊ំហ្នឹងហី?

ខ៖ ចាំហ្នឹងហើយស្លាប់នៅដៃញ៉ុម ពន្ទរលើស្មាទៅ ទារកបាយស៊ី គ្មានបាយអោយកូនស៊ី។

ក៖ អើយអ៊ំអើយឈឺចាប់ប៉ុណ្ណាទៅអ៊ំ?

ខ៖  ឈឺចាប់ណាស់កូនអើយអ៊ីចឹងបានញ៉ុមនិយាយថាជំនាន់
រឿងក្នុងទូរទស្សន៍ហា៎មិនបានមួយចំនិត មិនបានកាលពីជំនាន់លន់ នល់
ហាពីជំនាន់អាពតទេ!!

ក៖ ហ៊ឺ!!

ខ៖ មនុស្សធ្វើបាបមនុស្សយើងផ្ទាល់ៗម៉ងហា៎!!
ដូចក្នុងទូទស្សន៍គេបញ្ចាំងគុកឥតជញ្ជាំងអីវ៉ាន់នោះ។

ក៖ ចា៎!

ខ៖ មិនបាន មិនបាន១០ទេ!! នៅ៩០ទៀតអារឿងហ្នឹង។

ក៖  អាពេលរឿងគេបញ្ចាំងពេល៧មករាម្ដងៗហ្នឹងហី?

ខ៖  ហ្នឹងហើយ!!មិនបានមួយចំនិតទេ!!

ក៖  ហ្នឹងគ្រាន់តែជាមួយផ្នែកទេអ៊ំហី?

ខ៖  គ្រាន់តែជាមួយផ្នែកទូចទេ!! បើរឿងពិតហា៎ខ្លាំងជាងហ្នឹង៩០ដងទៀតណោះ !!

ក៖  អូយអ៊ំអើយ ញ៉ុមហា៎ញ៉ុមមើលរឿងអា អើយ មុនដំបូងគេ!!

ខ៖  ក្មេងសារក្រោយគេមិនដឹងទេ!!ក៖ ចា៎!!ខ៖ ជំនាន់ពួកហ្អែងមិនទាន់ដឹងទេ
មិនដឹងមិនទាន់កើតផងហ្នឹង!!

ក៖  ញ៉ុមមើលរឿងអីគេ ដំបូងគេសម្លាប់ឪពុករបស់ញ៉ុមហ្នំអ៊ំ
អេនជីលីណាជូលីគាត់ជាអ្នកថតហ្នំ អ៊ំហើយឡើងមើល ហ្នឹងម៉ែញ៉ុមថាតិចតួចបំផុតទេ!!

ខ៖ ហ្នឹងហា៎មីអូនញ៉ុមប្រាប់ហា៎ថា១០០ចំរៀក១០ទេ នៅ៩០ទៀតហ្នំបានប៉ុន!!ញ៉ុមប្រាប់!!

ក៖  សាហាវម៉ងអ៊ំហោ?

ខ៖ រឿងពិតដែលញ៉ុមហែលបានមកដល់ពេលហ្នឹងហា៎!!ក៖ ចា៎!!ខ៖
ដែលបានមករស់ដល់ពេលហ្នឹងហា៎!!មិនមែនធម្មតាទេ!!

កះ  ហ្នឹងហើយអ្នកដែលរួចផុតពីជីវិតពីប៉ុល ពតហ្នឹងហាំ!!

ខះ ហ្នឹងហើយ ហ្នឹងហើយ !!

កះ សុទ្ធតែជីវិតថ្លៃខ្លាំងណាស់អ៊ំ!!

ខះ  ហើយបើគេអោយយើងទៅដឹងគុណ
ទៅដឹងគុណអាណាបើបើអ្នកអាយើងដឹងគុណហ្នឹងវាធ្វើអញ្ចឹង!!

កះ  អ៊ំអាហ្នឹងអ៊ំ
ញ៉ុមដឹងញ៉ុមជ្រាបនៅក្នុងចិត្តញ៉ុមខ្លាំងម៉ង!!មួយៗគេដឹងទាំងអស់ហ្នឹងអ៊ំអើយ!!តែគ្រាន់តែអត់មានអ្នកណាគេនិយាយ!!

ខះ  មួយៗដឹងទាំងអស់!! ខឹងហាំ!!

កះ  ចាំ អត់មានធ្វើអីគេចេញអ៊ំណោះ?

ខះ  ទៅគ្រាន់តែដឹងបានតែមួយដឹងមួយដឹងហ្នឹង
យើងហ៊ានមើល!ថ្ងៃមួយគេចាប់យើងឥតអំពើរពិបាកឥឡូវហ្នឹងៗនិយាយអីចឹងតិចគេដឹង!!

កះ  អត់អីទេអ៊ំគេអត់ខ្វល់រឿងមួយហ្នឹងទេ!!

ខះ  យើងគ្រាន់តែខ្លាច!!

កះ  គេអត់មានស្តាប់អីទេ យើងគ្រាន់តែឯកសារទៅថ្ងៃខាងក្រោយទេ
អត់មានទៅយកទោសពៃអីអ្នកណាគេទេ!!គ្រាន់តែជាប្រវត្តិអីអញ្ចឹងវ៉ាន់ទេ
តែគ្រាន់តែថារឿងនយោបាយយើងទុកមួយផ្នែកយើងអត់មានពាក់ពន្ធ័អីហ្នឹងគេទេយើងមិនបាច់យកមកនិយយាទេ!!

ខះ  យើងយកតែរឿងយើង!!

កះ  ចាំហ្នឹងហើយ!!អញ្ចឹងអ៊ំដល់ពេលស្វាមីក្រោយគាត់ឈ្មោះអីគេវិញ?

ខះ ស្វាមីក្រោយគាត់ឈ្មោះហេង!!

កះ អីគេវិញ?

ខះ ហេង!!។

កះ ហេង??

ខះ អៀវ ហេង អៀវ ហេង!!

កះ  អៀវ ហេង ?

ខះ ចាំ!!

ខះ ឥឡូវគាត់អនិច្ចាកម្មដែរ?

ខះ  ខូចហើយ ចាំ!!

កះ  មូលហេតុអីដែរអ៊ំ?

ខះ  គាត់ឈឺលើសឈាម!!

កះ ហ្ហ៎!!

ខះ គាត់អាយុច្រើនហើយ ៦៩ហើយបានគាត់ស្លាប់!!។

កះ ចាំអញ្ចឹងអាយុច្រើនដែរហើយហ្នឹងបានគាត់ស្លាប់ហ្ហ៎!!

ខះ គាត់ឈឺឡើង៦ ៧ឆ្នាំហើយអូនអើយពិបាកណាស់ ខុសពីខ្ញុំ!

កះ ម៉េចវិញអ៊ំ?

ខះ  លក់ដំបូលនៅបាត់ហើយ គាត់ឈឺយូរពេកណាស់កូនជួយផងអីផងសព្វគ្រប់ប្អូន ឈឺឡើង៧ឆ្នាំមីអូនឯងគិតមើល!!កះ ចាំ!!ខះ ទៅដាំបាយអោយប្ដី ទៅមូលជើងខោ មនុស្សចាស់ ដូចកូនឯងបត់ជើងបត់ដៃនោម បត់ជើងធំ បត់ជើងតូចមិនត្រូវការលាងមិនត្រូវការគក់ ភួយ មុងអីៗ ៤ហ្នឹងកន្ទេល៣ ៤ទៅ ដល់ពេលលាងរាល់ថ្ងៃ។

កៈ គ្រាន់តែលើសឈាមសោះហ្នឹងជំងឺ?

ខៈ
ចុះប្ដីលើសឈាមគាត់ងាប់មួយចំហៀងខ្លួនគាត់ដើបអត់រួច!!ទាល់តែយើងប្រែទាល់តែយើងលើកគាត់។

កៈ ហ៊ឺ!!

ខៈ បត់ជើងមិននៅមួយកន្លែងធ្វើអីមិននៅមួយកន្លែង។

កៈ ហ៊ឺៗ!!ហើយអញ្ចឹងអំមិននៅមើលថៃគាត់មករហូតហើយអញ្ចឹង?

ខៈ មើលថៃរហូតហ្នឹង មិនមែនថៃរហូតទេ ដូចថាពេលណានេះទៅអើតមើលទៅ ធ្វើបាយធ្វើអីហើយទៅហ្នឹង អោយគាត់ហូបអោយគាត់បញ្ចុកហ្នឹងគាត់អីហ្នឹង បញ្ចុកគាត់អីសព្វគ្រប់ហើយអីហ្នឹងមើលគាត់អីទៅផ្លាស់ មើលថាគាត់នោមយើងផ្លាស់ខោផ្លាស់អាវផ្លាស់កន្ទេលអីហ្នឹងលាងហើយអីហ្នឹងបានចាប់ផ្ដើមរត់មកអុត។

កៈ ចាំ!!

ខៈ អុតហើយរត់ទៅមើលទៀត បើយើងមិនរត់ទៅមើលយើងបានអីស៊ី។

កៈ ចាំ!!

ខៈ បើលុយនៅតាមមើលគាត់រាល់ថ្ងៃមិនមែនអោយគាត់តឈឺដេកនៅកន្ទេល យើងអោយគាត់ទៅគេចាប់សរសៃនៅឯណាឯណីយើងគ្រប់កន្លែងទៅណាស់!!

កៈ ហ៊ឺៗ!

ខៈ មិនមែនតែនេះទេ អោយគេមើលគ្រប់កន្លែងទៅ!!

កៈ អ៊ីចឹងត្រូវមើលត្រូវអីដែរអំហេ?

ខៈ មើលគាត់ឡើង៦ ៧ឆ្នាំ ឈឺខ្លាំងជាងគេ៣ឆ្នាំ។

កៈ ហ៊ឺៗ!!

ខ៖ ៣ឆ្នាំសុទ្ធតែលុយសុទ្ធតែវេទនាហើយ!!

ក៖ ចាប់ម៉ងអ៊ំណោះ?

ខ៖ ចា៎!!

ក៖ អ៊ំមានកូនជាមួយអ៊ំប្រុសប៉ុន្មាននាក់ប្ដីក្រោយ?

ខ៖ ៣។

ក៖ ឈ្មោះអីគេខ្លះកូន?

ខ៖ ឈ្មោះហេងស្រីមុំ។

ក៖ ឈ្មោះហេងស្រីមុំមួយ!!

ខ៖ ចា៎!!

ក៖ ហេងអីគេទៀត?

ខ៖ ហេង សុផាន់ណាមួយ!!

ក៖ បងប្រុសមែន?

ខ៖ មិនមែនទេ នៅជាមួយប្រពន្ធហ្នឹកំពុងតែលក់មាន់អាំងហើយក្រូចអាំងនៅមុខនោះ !!

ក៖ ចា៎!!ហើយអ្នកណាគេមួយទៀត?

ខ៖ នឹង សុផានិត!!

ក៖ សុផានិត ហ្នឹងតែ៣នាក់ហ្នឹងទេអ៊ំណោះ?

ខ៖ ចា៎!!តែ៣ទេ ប្រុស២ស្រី១។

ក៖ ចា៎!!

ខ៖ មីស្រីហ្នឹងបង។

កៈ តែកូនពេលមុនមួយដែរ តែពេលមុនស្លាប់ហើយប្តីមុន!!

ខៈ  ប្តីមុនស្លាប់មួយហើយ!!

កៈ ចា៎!!តែប្តីក្រោយនៅទាំង៣អំណោះ?

ខៈ  នៅទាំង៣ កូនប្តីមុនងាប់អស់ហើយគ្មាននៅទេ!!ងាប់ប៉ុល ពត។

កៈ  ចា៎ បែកប៉ុល ពតហើយបានស្លាប់ហើយអំណោះ?ហា៎ច្រឡំ!!របៀបថា

ខៈ  ជំនាន់ប៉ុល ពត។

កៈ  របៀបថាប្តីក្រោយបែកប៉ុល ពតបានស្រលាញ់គ្នាមែន?

ខៈ  អត់ទេគេរៀបអោយជំនាន់ប៉ុល ពតអាពតរៀបអោយប្តី អោយប្តីមួយទៀតហា៎!!

កៈ តាមពិតផ្ទុលគ្នាតើអំហេអត់មានស្គាល់គ្នាហងហី?

ខៈ  គេផ្ទុលគេអោយយើងយក យើងមិនយកគេអោយយើងជំលៀសទៅនៅឯណាណោះ!!

ជិតព្រៃភ្នំឯណាយើងណោះ យើងងាប់នៅហ្នឹងម៉ងហា៎ យើងមិនធ្វើតាមគេ។

កៈ ហ៊ីខ្លាំងណាស់!!

ខៈ  យើងនៅស្រុកហ្នឹងហា៎យើងដើរពីកន្លែងដែរយើងនៅអី
នៅកំពង់ធំហ្នឹងហា៎នៅឯកន្លែងស្ទោងហ្នឹងហា៎ទំរាំតែទៅដល់ ៣០ ៤០គីឡូដី។

កៈ ចា៎!!

ខៈ ដើរទៅ ដើរតាំងពីព្រលឹមដល់ល្ងាចដើរមិនដល់ផង!!!ស្រុកហ្នឹងអត់មានពន្លឺថ្ងៃទេ
ដើមឈើធំៗកាប់រាល់ថ្ងៃហ្នឹងដែលថាគេនៅហ្នឹងហ្នឹង!!

កៈ ចា៎!!

ខៈ ព្រៃដែលគេកាប់អស់ហ្នឹងហា!!

កៈ ហ្នឹងហើយ!!

ខះ មួយថ្ងៃទល់ល្ងាចអត់មានពន្លឺថ្ងៃ ចុះដូចពពួកអាមែកឈើខៀវៗតាំងពីព្រឹករហូតដល់ថ្ងៃបើយើងមិនយកប្តីតាមគេ គេអោយយើងទៅនៅហ្នឹង គេអោយជំលៀសទៅនៅហ្នឹង!!!ហើយយើងមិនចាញ់ងាប់!!

កះ ហើយអញ្ចឹងក៏យកទៅ?

ខះ យកទៅ!!

កះ ហើយក៏ស្រលាញ់គ្នាដែរទៅ?

ខះ ស្រលាញ់ដែរទៅ ហើយបើគេនេះហើយមិនយកធ្វើម៉េច!!

កះ ចាំ!!

ខះ បានមកបានកូន៣មកអីចឹងទៅ!!រាល់ថ្ងៃហ្នឹង ហើយបានគាត់ងាប់ចោលបាត់ទៅ!!

កះ គាត់កំលោះតើអ៊ំហេ?

ខះ គាត់ពោះម៉ាយដែរដែលថាកូនគាត់២ហ្នឹង!!

កះ ហ្ហំហ្នឹងហើយអ៊ំប្រាប់ដែរ!!ឥឡូវអ៊ំចូលជីវិតអ៊ំចូលដល់ពេលជំនាន់លន់ នល់ សិន មុនចូលដល់សង្គ្រាមប៉ុល ពត អ៊ំជួបរឿងអីគេខ្លះអាគ្រាប់ផ្លោងហ្នឹងហ្ហំ??

ខះ គ្មានទេ យើងនៅភ្នំពេញហ្នឹងយើងមានជួបអី!!យើងគ្រាន់តែនៅចាំមើលប្តីយើងពេលទៅអញ្ចឹងហាំ!!គ្មានជួបអីទេ គ្រាន់តែយើងភ័យហាំ!!

កះ ចាំ!!

ខះមើលទៅឃើញអាពេលយើងខ្លាំងមែនទៅ ឧទាហរណ៍យើងឆេះ ឆេះហាងសាំងនៅពោធិ៍ចិនតុង ឆេះនៅហាងណាទេ!!!ឆេះនៅឯណាឆេះនៅកណ្តាលមកឆេះអីនៅណា!!

កះ ផ្អើលម៉ងអ៊ំហេ?

Commented [1]: មើល

ខ៖ឆេះយើងមើលឃើញ ទៅឈរមើលផ្ទះថ្មី៣ ៥ជាន់ណោះ។

ក៖ ចាំ!!

ខ៖ ឃើញទាំងអស់ជុំវិញ។

ក៖ តែគ្រាន់តែថានៅក្នុងភ្នំពេញសុវត្ថិភាព។

ខ៖ សុវត្ថិភាពអត់អីទេ
យើងចេះតែនៅអញ្ចឹងទៅណាស់!!ការពារការពារទាល់តែខ្លាំងតើបានគេជំលៀសយើងចេញតើ!!ខ្លាំងមែនទែនញ៉ុមទៅជ្រកនៅផ្សារអូរឬស្សី!!

ក៖ ម៉េចទៅអ៊ំពេលវាខ្លាំងមែនទែនហ្នឹងម៉េចទៅ?

ខ៖  ខ្លាំងមែនទែនទៅគេមានកាំភ្លើង ពួកអាតូចគេមានប៉ុនអាកូនចៅយើងហ្នឹង!!

ក៖ អាហ្នឹងពេលប៉ុល ពតមក?

ខ៖  គេមានពួកប៉ុល ពត ពួកខ្មែរក្រហមគេចូលមក !!

ក៖ ចាំ!!

ខ៖ គេចូលមកមកដល់កន្លែងមកដល់ភ្នំពេញហ្នឹង!!ដេញពួកហ្នឹងរត់!!

ក៖  អញ្ចឹងអ៊ំពេលមានប្តីម៉ងនៅភ្នំពេញឬក៏អ៊ំនៅតាមខេត្តកំពង់ចាម?

ខ៖  ពេលមានប្តីមិនមាននៅជំនាន់អាពតពេលមកនៅ!!

ក៖  អត់ទេ ពេលមានប្តីមិននៅក្នុងជំនាន់លន់ នល់ហេ?

ខ៖  ហ្នឹងហើយនៅជំនាន់ លន់ នល់ នៅជំនាន់លន់ នល់ហ្នឹងនៅភ្នំពេញតើ!!ក៖ ហ្នុំ!!ខ៖ នៅភ្នំពេញណោះទេ!!

ក៖  ការហើយនៅភ្នំពេញម៉ងហេ?

ខ៖ ការហើយនៅភ្នំពេញ ដាច់ផ្លូវអស់កូនឯងទៅណារួចមិននៅហ្នឹង!!

កៈ  ដឹងហែលទៅណារួចទេអំណោះ?

ខៈ  ដឹងហែលទៅណារួចដាច់ផ្លូវអស់ហើយ!! ហ្នូអាផ្លូវបាត់ដំបងដាច់អាផ្លូវកំពង់ឆ្នាំងឯណា កំពង់ចាមដាច់ទាំងអស់កូនឯងមានផ្លូវឯណាទៅ!!អត់មានទេ នៅដូចរិលនៅតែនេះអញ្ចឹង!!ដូចអណ្ដើកនៅក្នុងនេះអញ្ចឹងដូចគ្នាអញ្ចឹងដូចគ្នាគ្មានខុសទេកូនឯង!!

កៈ  តែគ្រាន់តែនៅក្នុងភ្នំពេញវាសុវត្ថិភាពជាងនៅតាមខេត្ត!!

ខៈ ហ៊ីល្មមថាតែមួយចប់រឿងបានគេជំលៀសយើងចេញទៅម៉ង!!

កៈ ចាំតែអ៊ំនៅក្នុងភ្នំពេញអត់មានឮគ្រាប់អីទំលាក់ណាហីម៉ង!!

ខៈ  មាន មាននៅគ្រប់កន្លែង!

កៈ  គ្រាន់តែនៅតាមខេត្តទេហី?

ខៈ
វាគ្រាន់តែដោយកន្លែងវាបាញ់គ្នាពព្រើពព្រុសដូចតែគ្នាហ្នឹងគ្រាន់តែវាដោយកន្លែងជុំវិញវាមិនមែននៅក្នុងហ្នឹងទេហាំ!!ជួនណាលមានដែរតែគ្រាន់តែវាតូចតាចវាមិនធំអីអញ្ចឹងណាស់!!វាចំយើងយើងគេចរួចអីអញ្ចឹងទៅ!!

កៈ អ៊ំសាលារៀនពេលហ្នឹងបិតទ្វារជិតឈឹង!!

ខៈ  បិតអស់ហើយ!!

កៈ វត្តអារាមអីលែងមានលោកហើយហី?

ខៈ  វត្តគ្រប់កន្លែងបិតអត់ហើយរត់អស់ហើយ
ដល់ពេលវាចូលមកដល់មែនទែនហាំយើងដូចថាគេជាន់លើអីអញ្ចឹងទៅ
គេទំលាក់មករពុំយកាំភ្លើងទៅខោអាវ ព្រោះជំនាន់ហ្នឹងទាហាន !!

កៈ ចាំ!!

ខ៖ ទំលាក់មករពុំយគ្មាននេះទេ ដូចចិនៗខ្លះវាសរស្ដោះ
ដូចចិនឥឡូវហ្នឹងវាអ្នកមានហ្នំវាសំលាប់ខ្លួននៅក្នុងហ្នឹងក៏មានដែរ!!នៅលើផ្ទះហ្នឹងម៉ង!!!

ក៖ អូយ!

ខ៖ វាអត់ចុះទេ!!

ក៖ ហើយមិនព្រមរត់សិនទៅសម្លាប់ខ្លួនធ្វើអី?

ខ៖  បើដើរទៅណារួចបើវាស៊ីស្អៀច
ស៊ីសុទ្ធតែសាច់ស៊ីបាយនៅតែលើផ្ទះម៉ែឪធាត់ៗស្អាតនៅអូរឬស្សីហ្នឹងកូនឯងមានអីក៏យកទៅ
មិនបាន យកបានទៅតែមួយចង្កេះ ចង្កេះហ្នឹងមានតែខោអាវមួយកំផ្លេចេះតែទូលដើរហើយ
មានស្អីក៏នេះដែរ ក៏យ៉ាប់!!

ក៖  ហ៊ីអុំអើយ!!

ខ៖  មានលុយក៏ចាយអត់កើតកូនឯង ខោអាវរកស្លៀកពាក់មិនបាន ជំនាន់ហ្នឹងដើរទៅ!!

ក៖  សម័យហ្នឹងគិតមើលពីទិដ្ឋភាពហ្នឹងសាហាវខ្លាំងណាស់អុំ!!

ខ៖ អូយមិនបានទេ ពួកវាក្មេងៗតូចៗល្អិតៗហ្នឹងចូលមកខ្មៅៗ។

ក៖  អាហ្នឹងពួកប៉ុល ពតអុំណេះ?

ខ៖  ហ៊ី!!មកពីខាងតាកែវមកពីខាងបូព៌ាហ្នឹងទៅ!!

ក៖  ញ៉ុមឆ្ងល់វាទៅកែនទ័ពមកពីណាញ៉ុមឆ្ងល់ដល់ហើយ!!

ខ៖  ពួកវាទូចៗហ្នឹង និយាយមានស្ដាប់គ្នាមកពីណា និយាយគ្នាញ្ញេវញ្ញាវ
ញ្ញេវញ្ញាវហ្នឹងនិយាយយួនដាក់គ្នាហ្នឹង!!

ក៖  យួនអីអញ្ចឹងទៅអុំណោះ?

ខ៖  ចា៎!!មានអាធំមានអាតូច!!

ក៖ ចា៎!!

ខ៖ វាធ្វើតាមតែចិត្តវាហ្នឹង!!

ក៖ ហ៊ឺ!!

ខ៖ យើងមិនព្រមធ្វើតាមវាមិនធ្វើតាមវា វានេះ មិនធ្វើតាមវា
ចំពុះទង់វាញ៉ុកភ្នែកយើងខ្វាក់ឥឡូវ!!អីចឹងទៅបាញ់ចោលភ្លូសដាក់នៅមុខទៀត!!

ក៖ ចំ!!

ខ៖ សាហាវណាស់!!

ក៖ វាបណ្តុះគំនិតពួកវាហើយអស់ហើយ បានអោយមកអញ្ចឹងអំណោះ?

ខ៖ វាបង្គាប់ពីកន្លែងវា
មកពីបន្ទាយវាមកហ្នឹងហើយ!!វាថាអោយទៅជើងគឺត្រូវទៅជើងវាថាអោយទៅត្បូងគឺត្រូវទៅត្បូង។

ក៖ អាណាប្រកែកបាញ់ចោល។

ខ៖
ដល់ពេលវាចូលមកដល់កូនវានៅត្រឹមសាលាគរុកោសល្យក៏ដោយឬក៏នៅត្រឹមផ្ទះហ្វ្លែងអីហ្នឹងហាំយើងថាទៅរកទៅយកវាទៅជុំហ្នឹងវាអត់អោយទៅទេ!!អត់ទៅហ្នឹងទៅណោះអោយទៅលិចទៅលិចទៅកើតទៅកើត!!

ក៖ ប្រកែកមិនបាន!!

ខ៖ ប្រកែកមិនបាន តែប្រកែកតែមួយមាត់វាបាញ់ម៉ងវាបាញ់ងាប់ហើយស្អូក!!

ក៖ អីចឹងមួយៗទៅតាមអញ្ចឹងទៅ!!

ខ៖ ហ្នឹងហើយគេថាទៅជើងទៅជើងទៅត្បូងទៅត្បូងកុំតវ៉ា!!

ក៖ តែពេលដំបូងអត់ដឹងប្រកែកដែរតើអំហោ?

ខ៖ អត់ទេអត់ហ៊ានប្រកែកទេ ព្រោះអីឃើញគេហើយយើងអត់ហ៊ានយើងចាំតែមើលគេចុះពីលើផ្ទះនោះ រិចបង្វិចទូលមួយបង្វិចអីចឹងមកដើរមក គេថាទៅនេះទៅនេះផ្លូវនេះមកហើយដើរមកអញ្ចឹងទៅ!!

ក៖ ចាំ!!

ខ៖ ដើរតាមផ្លូវដឹងតែតាមផ្លូវចុះខុសពីផ្លូវវាក៏មិនបានដែរយកចំពុះទង់រុកខ្វាក់ភ្នែកឥឡូវហ្នឹងគ្រាន់ដើរ!

ក៖ ហេពួកអាជំងឺយកនេះ!!

ខ៖ អូយសាហាវណាស់ញ៉ុមប្រាប់មីអូនឯងទៅ!!

ក៖ អាហ្នឹងថ្ងៃដំបូងដេញចេញពីភ្នំពេញហ្នឹងមែនអ៊ំ?

ខ៖ ហ្នឹងហើយ គេដេញយើងថាទៅ៧ថ្ងៃចូលវិញ គេអោយចូលវិញ!!

ក៖ បោកសោះ!!

ខ៖ ហ្នឹងហើយអត់អីទេ ទៅតែ៧ថ្ងៃវាអោយចូលវិញមិនបាច់យកអីទៅទេ!!

ក៖ ឥឡូវអ៊ំនិយាយមើលថាអាដល់ពេលចូលក្នុងសង្គ្រាមប៉ុល ពតជីវិតរបស់អ៊ំជួបរឿងអីគេខ្លះវិញ?

ខ៖ អត់មានជួបរឿងអី កូនឯងគិតទៅសង្ខារហ្នឹងដូចបានសុខដែរកូនដូចថាវាចេះតែមានសំណាងដូចជាមានដែរវាអត់អត់ទេ។

ក៖ ចាំ!!

ខៈ អត់សូវនឿយហត់នឹងគេប៉ុន្មានទេ វាអោយធ្វើអង្ករ
វាអោយស្រោចទឹកបន្លែនៅជិតៗភូមិ!!កៈ ចាំ!!ខៈ
វាដូចត្រូវប្រធានក្រុមប្រធានកងត្រូវជាមួយអ៊ំ!!

កៈ ហ្ហំហ្នឹងហើយ!!

ខៈ ត្រូវគ្នា ធ្វើអង្ករបានអង្ករស៊ីហើយ
ដំបូងឡើយទៅដំបូងឡើយ!!ធ្វើអង្ករបានអង្ករស៊ីអញ្ចឹងទៅណាស់។

កៈ ចាំ!!

ខៈ ទៅមុនគេ ដល់ពេលទៅស្ទូងអញ្ចឹងគេអត់ប្រើអោយយើងទៅស្ទូងទេ ញ៉ុមខ្លាចឈ្លើង
លោរក្រែរលោស្ទូងខ្លាចលោរមានឈ្លើងអញ្ចឹងណាស់កូនហាំ!!

កៈ ហ្នឹងហើយ!!

ខៈ អើយទៅដំបូងមិនដែលស្គាល់អញ្ចឹងហាំ
ហើយផ្ទះគេមានស្រះពីខាងក្រោយអញ្ចឹងហាំគ្រាន់តែលូកទឹកលាងជើងមកហើយហ្ស!!សួរថា
សត្វអីហ្នឹង មិនដែលស្គាល់ផងអត់ស្គាល់។

កៈ ចាំ!!

ខៈ គេថាឈ្លើង
ឈ្លើងស្អីគេមិនដែលស្គាល់ផងនៅស្រុកចំការមានឈ្លើងមកពីណាហាំដល់ពេលហើយមកនៅ
អាម៉េចថាមិនធម្មតាកូន
ដល់ពេលហើយឧបមាថាគេអោយយើងធ្វើហ្នឹងគេអត់មានការងារធ្វើអង្ករធ្វើស្រូវហើយគេអោ
យយើងទៅ ទៅដកសំណាប់ ដកសំណាប់ម្នាក់សុទ្ធតែ៥ភ្លូន។

កៈ ចាំ!!

ខៈ អ្នកណាគេស្អប់គេអោយដកប៉ុណ្ណឹងដកអោយបាន៥ភ្លូន
អ្នកណាគេស្រលាញ់យើងដកតែ៤ ៥កណ្តាប់ទៅផ្ទះចុះ
មិត្តឯងទៅផ្ទះចុះគេចូលចិត្តយើងអញ្ចឹងណាស់!!

កៈ ចាំ!!

ខៈ ហ្នឹងមេកងស្រីហ្នឹងហាំហើយយើងក៏ចេះដែរ
ពេលណាយើងបានអីយើងអោយគេព្រោះស្រុករដូវហ្នឹង យូរៗចែកអោយថ្នាំបន្ទាយ
គេហៅថ្មំបន្ទាយថ្មំកំពង់ចាម ថ្នាំខ្លាំងហ្នឹងហាំ!!

កៈ ចាំ!!

ខៈ ពួកវាចូលចិត្តអាហ្នឹងណាស់បានមួយប៉ាវមួយប៉ាវយើងអត់ចេះចុកអោយទៅវាទៅ!!

កៈ ហ៊ឺៗ!!

ខៈ បានអីហូបបានអីចេះតែផ្ញើរអោយទៅ ជូនណាលវាវាងចូលចិត្តយើងផង
ទាំងស្រីទាំងប្រុសវាចូលចិត្តយើងយើងចេះតែធ្វើបុណ្យល្អក៏វាមិនដឹងវាមិនអីហាំ!!អត់អីកូនឯង
ស្រួល គេអោយតែក្រវិល ក្រវិលនៅក្នុងភូមិគេអត់អោយទៅណាទេ!!

កៈ  ក៏អត់មានអ្នកណាគេយកទៅសម្លាប់អីណាដែរអំណោះ?

ខៈ អត់ទេ អត់ទេព្រោះយើងសុទ្ធតែកូនសុទ្ធតែស្រីហើយយើងមេម៉ាយយល់ហេ
កាលហ្នឹងយើងមិនមេម៉ាយ។

កៈ ហើយអ៊ីចឹងដល់ពេលម៉េចពេលហើយអំស្រួលដែរតែហេតុអីដល់កូនអត់មានអីហូបវិញ?

ខៈ ចាំ?

កៈ  ពេលហ្នឹងថីបានកូនស្លាប់ហ្ន៎?

ខៈ ហេរស់ស្រួល ប៉ុន្តែគ្រាន់ពេលណាមិនស្រួលប៉ុនថាដល់៣
៤ឆ្នាំកូនឯងគិតមើលទៅមិនមែនស្រួលរហូតណា!!

កៈ ហ្ន៎មានពេលពិបាកដែរ?

ខៈ  មានអាពេលពិបាកដែរគ្រាន់តែពេលពិបាកវាពិបាកក៏វាពីបាកដែរនៅក្នុងភូមិវាអត់ស៊ី
វាអត់អីស៊ី!!

កៈ ចាំ!!

ខៈ មួយឆ្នាំវាធ្វើបុណ្យជ័យជំនះគេ
គេអោយបាយគេប៉ុនកាពងគេមកមិនមែនអោយរាល់ថ្ងៃណា!!ងាប់ហើយ
បបរមួយកំប៉ុង៨នាក់៩នាក់!!គិតមើលបានប៉ុន្មាន បានម្នាក់២ស្រាបព្រាហ្នឹង បបរ!!

កៈ ហ្នឹងហើយ !!
អ៊ំអើយអ៊ំ!!ហើយអ៊ំពេលហ្នឹងអ៊ំដែលឃើញគេយកមនុស្សទៅសម្លាប់ចោលទាំងខ្សែទាំងខ្សែអី
អត់?

ខៈ  អត់ អត់ដឹងទេ!!!តែដែលធ្លាប់ឃើញថាពេលព្រលប់ឡើងគេថាគេមកគោះទ្វារហើយ
វាមកគោះទ្វារហើយ គោះទ្វារហៅថាអង្គការគេអញ្ជើញ
អញ្ជើញយើងអោយទៅនៅណាទៅនៅណាទៅទៅតាមភូមិអញ្ចឹងទៅ
តាមពិតយកទៅសម្លាប់ចោលហើយ យកទៅទាំងអស់ ទាំងគ្រួសារទាំងគ្រួសារហ្នឹងម៉ង!!

កៈ ហ៊ឺៗ!!

ខៈ ញ៉ុមប្រាប់កូនឯងទៅយកទៅមួយគ្រួសារមួយគ្រួសារញ៉ុមបន់ដែរ!!
មើលញ៉ុមនិយាយប្រាប់មីអូនឯងរឿងមួយហាំ ញ៉ុមនិយាយបានអត់?

កៈ និយាយមកអ៊ំ និយាយមកអត់អីទេ!!!

ខៈ  ចាំមើលមុនគេហៅមនុស្សទៅសម្លាប់ហាំ មុនអាពួកបូព៌ាគេមកសម្លាប់យើងហាំ!!

កៈ ចាំ!!

ខៈ គេហៅទាំងពូជៗ គ្រូបង្រៀនទៅ  ប៉ូលីស ទាហានទៅ គេដឹងហាំ
បៀៗគេយកទៅហើយគេមិនសូវចូលចិត្តគេយកទៅហើយ
ល្ងាចឡើងវាយករទេះគោយកមកដឹងទៅហើយព្រលប់ៗម៉ោង៧ហ្នឹងវាមកគោះទ្វារហៅហើ
យ។

កៈ ហ៊ឺៗ!!

ខះ មុនធ្វើការយើងមិនធ្វើបាយធ្វើអីស៊ីយើងលួចលាក់ស៊ីទៅណាស់របស់យើងហ្នឹង យើងតើបស្រូវបានខ្លះហ្នឹងបានយើងបុកក្នុងដីហ្នឹង ក្រាលក្រណាត់បុកកូនណាស់!!

កះ បុកអីគេវិញអ៊ំ?

ខះ បុកស្រូវបុក បាតលាននៅសល់យើងទៅជីករណ្ដៅដាក់បុកទៅណាស់!!

កះ ចាំ!!

ខះ ក្រាលក្រណាត់អញ្ចឹងទៅបុក ធ្វើអានេះទៅ មានអុសមានឈើអញ្ចឹង បុកៗអ៊ំទៅអញ្ចឹងទៅ ដាក់ដាំនៅក្នុងកំសៀវអញ្ចឹងទៅ ស៊ីទឹកត្រីស៊ីអីអញ្ចឹងទៅ!!យើងដាំទឹកទៅ ដាំក្នុងកំសៀវទៅអាណាមកបើកកំសៀវយើងមើល ខ្លាចគេនេះណាស់!ហ៊ើថាមិនធម្មតាទេ ថាវេទនាណាស់។

កះ ខ្លាំងម៉ងហ្នឹងហាំ!!

ខះ ខ្លាំងម៉ងកូនឯង !! ដល់ពេលហើយអាហ្នឹងក៏ ហេចង់ភ្លេចហ្នឹងហិ!!

កះ ចាំ!!

ខះ ដល់ពេលគេមក គេមកហៅយកទៅបាត់ទៅ ដល់ពេលយើង ញ៉ុមនិយាយរឿងញ៉ុមយល់សប្ដិ!!

កះ ចាំ!!

ខះ មុនដំបូងគេ គិតថាយល់សប្ដិហ្នឹងត្រូវហើយកូនណាស់ មុននឹងគេមកហៅទៅសម្លាប់ចោលទាំងពូជទាំងពូជដឹងហាំកូនឯងញ៉ុមយល់សប្ដិឃើញកូនឯងដឹងម៉េចទេ!!ឃើញគេធ្វើដូចមានកំផែងអីចឹងវាលវាសំរាប់ចុះកប៉ាល់ហោះអញ្ចឹងណាស់ ធំមានប្រកាន់ដៃនៅជុំវិញហ្នឹងមានជណ្ដើរឡើងទៅ ហើយគេមានដាក់អន្ទ្យម អន្ទ្យមហ្នឹងដូចថាមួយគ្រួសារមានបីនាក់គេដាក់បីនាក់មានប្រាំនាក់គេដាក់ប្រាំនាក់ !!

កះ ហ្នឹងយល់សប្ដិអ៊ំហោ?

ខះ យល់សប្ដិ!!

កៈ ចាំ!!

ខៈ យល់សប្តិតែស្តែងហាំ!!មានប្រាំបីនាក់គេដាក់អង្ករប្រាំបីជុំវិញមួយជុំហ្នឹង ដល់ពេលហ្នឹង ព្រលឹង ព្រលឹងញុំមហ្នឹង ញុំមយល់សប្តិថាឃើញដើរឡើងទៅជាមួយកូនដែរ មិនមែនអត់ទេណាស់ឡើងទៅដល់ស្រាប់តែឃើញអន្សមអត់ស៊ីយូរហើយមិនចង់ ហើយដល់វា វាប្រាប់ថា អាអ្នកដែលនៅយាមហ្នឹងគេថា គេប្រាប់ថាអត់ទេអឹងឯង អឹងឯងគ្រួសារអឹងឯងគេអត់មានត្រូវអោយស៊ីទេអន្សមហ្នឹង ថាអ្នកណាយកអន្សមហ្នឹងស៊ីត្រូវតែឡើងកប៉ាល់ហោះជាមួយគេ ដល់ពេលហើយវាអត់អោយយើងស៊ី ដល់ពេលអត់ហើយយើងខឹងវា ចិត្តហ្នឹងឡើងយំ ឃ្លានចង់ហ្វុំខានស៊ី៣ ៤ឆ្នាំហ្វុំកូនឯងគេអោយទៅរួចគេដេញយើងចុះមកវិញ ដល់ពេលអ្នកយកអន្សមឡើងយកអន្សមគេស៊ី៣នាក់ឡើងស៊ីអន្សម៣ហ្នឹងគេអោយឡើងកប៉ាល់ហោះឡើងយកទៅបាត់អស់យើងរួចខ្លួន ដឹងខ្លួនរួចខ្លួនអត់អី។

កៈ ចាំ!!

ខៈ តែព្រលប់ឡើងកូនអើយអង្គុយភ័យខ្លាចគេមកគោះទ្វារហៅមិនដឹងអីក៏មិនដឹង គេនៅជាមួយ២ ៣គ្រួសារគេមកគោះហៅទៅដូចថាឈ្មោះឃឹមអញ្ជឹងទៅ ទៅម៉ែកូន៣នាក់ ឪមួយម៉ែមួយកូនមួយហ្នឹង ទៅឡើងរទេះទៅទៅទៅ ប្រមែប្រមូលតវ៉ាន់ហ្នឹងមានចានមានឆ្នាំងទៅនៅឃុំគេហ្នឹងទៅនៅគេបាត់ ស្អែកឡើងមកគោះទ្វារជិតផ្ទះយើងទៀតហើយ ស្រាប់!!!

កៈ  ហើយអញ្ជឹងមិនព្រលឹងចុងសក់ហើយកូនអើយ!!!

ខៈ  ព្រលឹងរាល់តែថ្ងៃហ្នឹងនិយាយអ៊ីចឹងព្រលឹងចុងសក់រាល់ថ្ងៃកូនឯងនិយាយអ៊ីចឹង!!

កៈ អើយ!!

ខៈ ដល់ពេលផុតពីហ្នឹងបានបន្តិចទៅដូចថាបានប៉ុន្មានថ្ងៃរាល់ថ្ងៃ ដល់ព្រលប់ឡើងដើរគោះគ្រប់កន្លែង អ្នកណាទៅ៤នាក់ទៅទាំង៤បាត់ទាំង៤ងាប់ទាំង៤ពេលមកស្រុកឥឡូវដឹងថាងាប់ អត់ឃើញមកស្រុកមិនដឹងថាងាប់!!

កៈ ហ៊ីៗ!!

ខ៖ អ្នកនៅបាភាយណ៍ស្រុកខ្ញុំហ្នឹងហាំ!!ក៖ ចាំ!!ខ៖ ដល់ពេលហើយគេអត់អោយអន្សមអត់ចែកអន្សមយើងយើងអត់ស៊ីយើងអត់ងាប់យើងអត់ទៅកូនឯងអត់បានឡើងកប៉ាល់ហោះនឹងគេ!!

ក៖ ហ៊ឺៗ!!

ខ៖ កូនឯងមុននឹងឡើងកប៉ាល់ហោះគេមិនអោយនំអន្សមហ្នឹងយើងស៊ីអួយយល់សប្តិហ្នឹងស្តែងអាក្រក់អាក្រីណាស់កូនឯងមើល!!ទៅដល់គេហៅហៅរាល់ថ្ងៃបានឡើងប៉ុន្មានម៉ឺនប៉ុន្មានពាន់អ្នកគិតទៅក្នុងនេះគេនិយាយហ្នំ!!

ក៖ ចាំ!!

ខ៖ អត់ដឹងដល់ពេលហើយចាប់ផ្តើមកំពុងតែស្ងួងៗស្រូវកូនឯងគេថាហ្នំគេមករំដោះគេមករំដោះ យើងអត់ដឹងសោះ។

ក៖ ពួកវៀតណាមចូលមកហ្នឹងហើ?

ខ៖ ហ្នឹងហើយពួកវៀតណាមចូល ពួកវៀតណាមមកជួយរំដោះជួយរំដោះរួចខ្លួនទៅរស់បានដល់ឥឡូវហ្នឹងទៅ ហ្នឹងកូនឯង!!

ក៖ ចាំ!!!

ខ៖ ញ៉ុមគិតទៅល្ងង់ណាស់ ល្ងង់ ទុកចិត្តទុកថ្លើមវាគ្មានគិតភ័យទេ គេថាចប់ហើយហ្នឹងហាំហ៊ីក្រែងលោរអាចប់ហ្នឹង
វៀតណាមវាមិនល្អជាមួយអញឬក៏ខ្មែរក្រហមវាមិនល្អជាមួយយើងដើរតាមផ្លូវតាំងពីស្វាងរហូតមកដល់ខេត្តកំពង់ចាមកូនឯងមើលប៉ុន្មានយប់ប៉ុន្មានថ្ងៃ!!

ក៖ អញ្ចឹងអំពេលនៅក្នុងសង្គ្រាមប៉ុល ពតហ្នឹងអំនៅស្វាង?

ខ៖ ហ្នឹងហើយនៅស្វាង។

ក៖ គេជំលៀសទៅហ្នឹងអំណោះ?

ខៈ គេជំលៀសទៅធ្វើការនៅហ្នឹងនៅស្រុកគេហ្នឹង
ដើម្បីធ្វើការនៅភូមិស្ពោហាកូននៅហ្នឹងហាំ!!

កៈ ចាំ!!

ខៈ កូនឯងដល់ពេល!!

កៈ អំបើសិនជាឥឡូវដល់ពេលរក រកឃើញទេអំនៅហ្នឹង?

ខៈ អត់ទេ លែងស្គាល់ហើយកូនណាស់ ពីមុនហើយឥឡូវវាខុសគ្នាដូចមេឃនឹងដីអញ្ចឹង
មើលតែភ្នំពេញយើងហ្នឹងដឹងហើយ ដល់ពេលហើយកូនឯងដឹងទេ ដល់ពេលនៅហ្នឹងទៅ
ដល់ពេលមកវិញ
មកវិញដល់ពេលថាហើយអញដល់ពេលដេកយប់អធ្រាតណាស់ជិះរទេះរុញហាំកង់នាំគ្នាអារ
ទេះនឹងកង់ហ្នឹងធ្វើដាក់ធ្វើជារទេះយើងរុញធ្វើដាក់ចង្ក្រានចានឆ្នាំងខោអាវគ្រាន់ដាក់បានខ្លះ
ក្រមាមកផ្លាស់តាមផ្លូវអ៊ីចឹងមកណាស់!! មកដល់យប់ឡើងដេកហើយ
ដេកលក់ស្រួលរំភើយក្បែរផ្លូវហ្នឹង
អត់មានដឹងថាក្រែងលោវាខឹងវាវិលមកវិញវាខឹងវាមកអារករយើងអីអត់ទេ
ហាក៏ខ្លាចយួនវាសុខចិត្តសម្លប់យើងអត់ទេ
ចឹអ៊ីចឹងបាននឹកក្នុងចិត្តថាដល់ពេលហើយភ័យខ្លួនកូនឯង
ដល់ហើយភ័យខ្លួន!!ដល់ហើយភ័យខ្លួនកូនឯងគិតទៅអញត្រង់ម្លេះស្រួលម្លេះស្លូតម្លេះហើយ
ត្រង់មែនទែនពីហ្នឹងជិត២០ថ្ងៃតាំងពីហ្នឹង ថាណាអាករតាមផ្លូវទាំងពូជទាំងអស់!!

កៈ ងាប់ហើយអាពេលជំលៀសមក ហាបែកមក!!

ខៈ ពេលជំលៀស ពេលបែកយើងមិនរៀបមកផ្ទះវិញ
បែកយើងមិនមកផ្ទះរៀងខ្លួនយើងមកដោយមធ្យោបាយម៉េចបានមកទៅស្រេចយើង!!

កៈ ពេលហ្នឹងតែគ្រាន់តែមានសេរីភាពបានដើរហើរវិញហើយអត់មានដូចមុនទេ!!

ខៈ ដើរហើរហ្នឹងប៉ុន្តែពួកយើងអត់មានខ្លាចសោះ យើងដឹងថាវាទៅអស់!!

កៈ ចាំ!!

ខ៖
ប៉ុនថាវាត់អស់ប៉ុនថាវានឹកឃើញខឹងពួកហ្នឹងអាករមួយក្រុមគ្រួសារងាប់អស់ដើរដេកតាមផ្លូវធ្វើស្រួល!!ថ្ងៃដើររកស្អី ត្រី កង្កែប ក្តាម ខ្យងស៊ីទៅ!!

(អ្នកដទៃ)៖ សម័យប៉ុល ពតហោ?

ខ៖ ហ្នឹងហើយ!!

ក៖ កំពុងសួរពីសម័យប៉ុល ពត!!

(អ្នកដទៃ)៖ អូយវេទនាណាស់មីអូនវេទនាណាស់!!

ក៖
ចាំហើយអ៊ីចឹងអ៊ំដល់ពេលអ៊ំដើរមកអញ្ចឹងហាំ!!អ៊ំមានឃើញសាកសពអីតាមផ្លូវអីស្លាប់អីអត់ទេ?

ខ៖ អត់ ដូចអត់មានកូន។

ក៖ អត់មានដែរហោ?

ខ៖ អត់មានទេកូនអត់មានទេ!!

ក៖ តែដល់ពេលក្នុងជំនាន់ប៉ុល ពតអាពេលអត់ទាន់បែកមកហាំ!អ៊ំមាននេះទេនៅក្នុងហ្នឹងដូចគេដូចរបៀបថាសម្លាប់ចោលនៅនឹងស្រែស្រែហ្នឹងមានទេ?

ខ៖ អត់មានទេ!!!អត់ទេ អត់មានទេ!

ក៖ បើសិនជាគេយកទៅសម្លាប់គេយកទៅឆ្ងាយអ៊ីចឹងហ្ន៎?

ខ៖ គេទៅឆ្ងាយគេទៅលាក់ការមិនអោយយើងឃើញទេ។

ក៖ ចាំ!

ខ៖ គេមិនអោយយើងដឹងទេ
ជូនកាលញ៉ុមលឺសួរគេនិយាយត្រង់ថាមែនមិនដឹងមែនញ៉ុមអត់អត់ដឹងទេព្រោះវាមិនបានទៅ

មិនឃើញ គ្រាន់តែលឺគេនិយាយវាធ្វើវាអា នៅសាលាកាលេសនៅកន្លែងស្មោងហ្នឹងហា៎
ឃើញវាអាឃើញជាក្ដារយួនអញ្ចឹងហា៎មានបង្កាន់ដៃអោយយើងអង្គុយអញ្ចឹងហា៎
អង្គុយទល់មុខគ្នាអញ្ចឹង បើកាលណាគេដឹកស្អី ឃើញគេដឹកឫស្សី
ឃើញគេដឹកទាំងឡានទាំងឡានអញ្ចឹងហា៎ មួយទ្រុងមួយឡានអ៊ីចឹង
ឡានកាំម៉ាស់ហ្នឹងឡើង២០ ៣០ធុងអីណោះ ដាក់អស់ប៉ុណ្ណាគេដាក់ប៉ុណ្ណឹង
ដាក់អស់ប៉ុណ្ណាគេដាក់ប៉ុណ្ណឹងយកទៅចាក់ហើយគេអោយយើងទៅប្រជុំ
ហៅយើងទៅប្រជុំហ្ន៎រាល់តែថ្ងៃ ប្រជុំហ្នឹង
ថ្ងៃធ្វើការព្រលប់ឡើងមិនហត់ល្ងាចទៅវាអោយយើងទៅ
ប្រជុំហើយបើប្រជុំកាលណាយើងងោកទៅយើងមិនអង្គុយលើបង្កាន់ដៃធ្វើអញ្ចឹង។

ក៖ ចា៎!!

ខ៖ អង្គុយហ្នឹងចេះតែងោកទៅអាណាដេកក៏ដេកទៅអាណានេះក៏នេះទៅ
ហើយដល់ពេលនេះទៅដល់ម៉ោងដល់នេះ ហ្ន៎ដល់ម៉ោង
គេអោយទៅផ្ទះហា៎!!គេអោយមកផ្ទះហ្នឹងវាឆ្ងាយដែរវាប្រហែលមួយគីឡូដីជាង
ពីរគីឡូអីដែរពីរក្នុងផ្លូវភូមិអ្នកស្រុកហ្នឹងទៅដល់កន្លែងសាលាកាលេសហ្នឹងឆ្ងាយណាស់!!កូន
សុទ្ធតែវាលស្រែ។

ក៖ ចា៎!!យើងមើលមិនអាចឃើញ
ឃើញគ្រាន់តែឃើញដើមត្នោតលឹមៗវាលមើលទៅនោះ!!ទៅមាត់ស្ទឹងអីហ្នឹងណាស់មីអូន។

ក៖ ចា៎!!

ខ៖
ដល់ពេលហើយអង្គុយៗអត់ងងុយដល់ពេលហើយងោករាល់ថ្ងៃអ៊ីចឹងទៅយើងមិនអង្គុយលើ
ក្រាបអញ្ចឹងទៅ
ហើយយូរៗទៅវាទាញអាគន្លឹះហ្នឹងមកវាមិនធ្លាក់ចូលរណ្ដៅអាស៊ីតហ្នឹងហើយយើងដឹង!!!ក៖
ហ៊ឺៗ!!ខ៖ អាហ្នឹងវាអ៊ីចឹង វាទំលាក់ចូលក្នុងហ្នឹង !!

ក៖  អ៊ីចឹងនៅក្នុងហ្នឹងវាជាគំរោងការរបស់វាឬក៏ម៉េចអ៊ំហី?

ខ៖ គំរោងការគេហ្នឹង គំរោងការវាធ្វើអញ្ចឹង។

កៈ  ទៅប្រជុំ ទៅប្រជុំអញ្ចឹងទៅ ធ្លាក់ចូលទៅក្នុងហ្នឹងទៅ!!

ខៈ  ហើយធ្លាក់ចូលទៅវាទាញគន្លឹះទៅសំរាប់ដាក់ចូលក្នុងហ្នឹងអោយវារលួយរលេសងាប់ទៅមិនធម្មតា វាធ្វើគ្រប់មុខ!!!

កៈ
ចាំ!!ញ៉ុមឆ្ងល់ខ្មែរគ្នាឯងសោះកើតគំនិតមួយថ្ងៃៗថាត្រូវធ្វើម៉េចសំលាប់ខ្មែរគ្នាឯងអោយបានអំណាស់!!

ខៈ ហ្នឹងហើយកន្លែងវាកន្លែងមន្ទីរវាមួយៗហា!!!

កៈ ចាំ!!

ខៈ មន្ទីរវាមួយៗខាងសេដ្ឋកិច្ចហាំខាងមើលពួកខាងមើលដូចថាខាងខុសត្រូវខាងនេះហ្នឹងហាំកន្លែងវាអត់មានអីក្រៅពីដំបង គល់ឬស្សី ដែកបំពង់ទីបហ្នឹង!!!

កៈ  អើយញ៉ុមឆ្ងល់ពួកវាចិត្តគំនិតម៉េច!! ប្តីប្រពន្ធវាម៉េចទៅអ៊ំបើវាអញ្ចឹង?

ខៈ  ពេលវាធ្វើយើងហើយសម្លាប់បាន
អាខ្លះវាអារយើងយកថ្លើមយកប្រមាត់យើងស៊ីបានចិត្តវាធំអ៊ីចឹងហ៊ានសម្លាប់ទៀត!!

កៈ អួយសាហាវម៉ង!!យ៉ាប់ណាស់អ៊ំអើយដល់ពេលអ៊ិចឹង!!
អ៊ំដល់ពេលបែកប៉ុលពតមកអ៊ំរស់នៅជាមួយនឹងប្តីតមករហូតអ៊ីចឹងមក?

ខៈ  ចាំ!!តមករហូតដល់តែគាត់ឈឺស្លាប់ទៅ!!

កៈ  ចាំ!!អ៊ំរកស៊ីអីគេខ្លះ ? ចាំមើលបែកពីប៉ុល ពតមកជាមួយស្វាមីហ្នឹងរកស៊ីអីគេខ្លះ?

ខៈ
ប្តីញ៉ុមដូចញ៉ុមថាគាត់ធ្វើជាងហើយពេលកន្លងមកដល់ពេលញ៉ុមនៅស្រុកបានបន្តិចទៅបានញ៉ុមមកនៅភ្នំពេញ។

កៈ ចាំ!!

ខៈ នៅភ្នំពេញញ៉ុមលក់កង់!!

កះ ហ្អ៎ !!

ខះ លក់កង់ លក់កង់នៅផ្សារអូរឫស្សី។

កះ ចាំ!!

ខះ
ដល់ពេលអញ្ចឹងទៅលក់កង់ហើយយូរៗទៅខ្ញុំពិបាកម្ចាស់ផ្ទះគេជួលផ្ទះគេនៅជួលលក់មុខផ្ទះគេនោះ!!

កះ ហ្អ៎ស្មានតែផ្ទះរបស់ខ្លួនឯង!!

ខះ រោងកុនប្រាសាទពេជ្រពីដើមហាំ!!កះ ចាំ!!ខះ កន្លែងហ្នឹង ដល់ហើយវាពិបាក
ធម្មតាតែយើងលក់មុខផ្ទះគេពិបាកណាស់មីអូន
កាលណាគេសួរម៉ូយអីចឹងគេទាក់យកម៉ូយយើង
ព្រោះយើងអត់ហ៊ានមាត់ទេយើងនៅផ្ទះគេគេមិនលែងជួលអោយយើងវាមិនរឿង!!

កះ ចាំ!!

ខះ ហើយអោយទៅគេទៅយើងទ្រាំ ទ្រាំ ទ្រាំ ទ្រាំក៏មិនបានយើងមកនៅតាខ្មៅនេះម៉ងទៅ!!

កះ ម្ចាស់ផ្ទះហ្នឹងគេលក់កង់ដែរ?

ខះ គេលក់កង់ដែរ បើយើងធ្វើផ្ទះគេ បើកាលណាយើងខឹងគេក៏យើងខឹងមិនកើតដែរ!!

កះ ចាំ!!

ខះ ខឹងគេទាល់តែគេលែងអោយយើងដាក់កង់ផ្ទះគេដែលគេជួលអោយយើងហ្នឹងហើយចាំ !!

កះ ហ្នឹងហើយតែមានបញ្ហាអញ្ចឹងហើយអំណោះ??

ខះ ចាំហ្នឹងហើយនឹកចេះតែភ័យ ពិបាកពិបាកដែរ ប៉ុន្តែរកបានទេ
រកបានហូបណាស់កូនណាស់!!

កះ ចាំ!!

ខ៖ ចំនេញបានស៊ីតើ!!
ដល់ពេលហើយនៅពីហ្នឹងមិនបានក៏មកពីហ្នឹងមកទៅទិញដីនៅក្នុងហ្នឹងទៅថោកៗចេះតែនៅទៅ!!

ក៖  ចាំ!!ដល់ពេលចេះពីភ្នំទៅនៅអាគារវប្បធម៌ណោះវិញអ៊ំណោះ?

ខ៖  ចាំហ្នឹងហើយនៅអាគារវប្បធម៌ហ្នឹងហើយ!!
ហើយហើយប្ដីញ៉ុមគាត់ក៏រកស៊ីធ្វើម៉ូតូអោយគេតិចៗតូចអីចឹងទៅ!!កំប៉ិកំប៉ុកអញ្ចឹងទៅ!!

ក៖ ហ៊ឹៗ!!

ខ៖ ហើយញ៉ុមនេះញ៉ុមអត់ទាន់អ៊ុតសៀវភៅទេ កាលហ្នឹងប្ដីរកស៊ីចិញ្ចឹម។

ក៖ អ៊ំចាប់ផ្ដើមពីអ៊ុតសៀវភៅឆ្នាំប៉ុន្មានមកវិញ?

ខ៖  យូរដែរ ប្រហែលជា១០ឆ្នាំហើយមិនដឹងទេនេះ។

ក៖ ហ៊ឹៗ!!

ខ៖ ១២ ១៣ឆ្នាំហើយមិនដឹងតាំងពីញ៉ុមអាយុ៥១ ៥២ណោះ!!៥២អីណោះយ៉ាង!!

ក៖ ចាំ!!អីចឹងយូរដែរហើយ!!

ខ៖ ធ្វើតពីមីម៉េចហ្នឹង!!

ក៖ ចាំ!!

ខ៖ វាអ៊ុតហើយញ៉ុមស្ដាយ ហើយវាទៅធ្វើការរោងចក្រទេ ក្រមុំវានៅធ្វើការរោងចក្រទេ
ដល់ហើយឈឺទៅវាលែងធ្វើទៅធ្វើក្រចកអីអញ្ចឹងទៅណាស់កូនញ៉ុមហ្នឹង!!

ក៖ ហ្វ៎!!

ខ៖ ហ្នឹងមកដល់ឥឡូវហ្នឹង។

កៈ
ឥឡូវហ្នឹងដល់ឥឡូវហ្នឹងហើយក៏ចប់ប្រវត្តិតាំងពីដល់ហ្នឹងទៅ!!!!អ៊ំរៀបរាប់តាំងពីណាពីណីមកគាស់អស់ហើយ។

ខៈ គាស់អស់ហើយហ្នឹងហើយអស់ហើយ។

កៈ ចាំ!!ឥឡូវអ៊ំមួយនេះគឺជាសំនួរមួយចុងក្រោយ
មានអីគេផ្ដែផ្ដាំកូនចៅជំនាន់ក្រោយអោយពួកគាត់ដើរលើផ្លូវម៉េចដែរហើយជៀសផុតពីផ្លូវម៉េចដែរអញ្ចឹងអ៊ំហាំ??

ខៈ ចាំ?

កៈ
ប្រាប់អោយគាត់ដូចជាថាចង់អោយកូនចៅជំនាន់ក្រោយអោយគាត់ជៀសផុតពីផ្លូវអីហើយអោយគាត់ដើរលើផ្លូវអីអញ្ចឹងហាអ៊ំណាស់?

ខៈ ដើរលើផ្លូវល្អប្រឹងរកស៊ីទៅ!!

កៈ ចាំហើយជៀសផុតពីអីអញ្ចឹងហាំ!!

ខៈ ខំប្រឹងរៀនខំប្រឹងរកស៊ីទៅ
ហើយោអោយបានដើរលើផ្លូវត្រូវផ្លូវល្អអញ្ចឹងទៅ!!កុំអោយវាដើរទៅលើផ្លូវខុសអញ្ចឹងទៅកូនណាស់។

កៈ ចាំ!!

ខៈ ប្រដេរប្រដៅវាទៅប៉ុណ្ណឹង។

កៈ ចាំហ្នឹងហើយ
ហេ!!ចាំអញ្ចឹងអរគុណច្រើនខ្លាំងមែនទែនអ៊ំសំរាប់ការសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ំនៅក្នុងថ្ងៃនេះអោយបានក្បោះក្បាយ។

ខៈ ហ្នឹងហើយចាំ!!

កៈ
អ៊ីចឹងអ្វីទាំងអស់កូនចៅរបស់អ៊ំគាត់នឹងបានស្តាប់ក៏ដូចជាមនុស្សជំនាន់ក្រោយគាត់បានសិក្សាពីជីវិតប្រជាជនខ្មែរយើងអញ្ចឹងណាស់អ៊ំណាស់!!

ខៈ ចាំ!!

កៈ ថាជួបរឿងអីគេខ្លះហ្នឹងនៅក្នុងជីវិតហ្នឹង!!ចាំអញ្ចឹងអរគុណច្រើនណាស់អ៊ំ។

ខៈ ចាំចាំ។